# មេរៀនទី ៥២៖ ព្រះប្រទានជ័យជំនះលើក្រុងយេរីខូរ

## យ៉ូស្វេ ៦៖១-២៧

មេរៀន(យូធូបលីង)៖ https://youtu.be/ie5bwZ4r-Vg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/xmr8ooTKTrI

**គោលបំណង៖** ព្រះអង្គតែងតែឈ្នះក្នុងគ្រប់ការទាំងអស់

**ខគម្ពីរចងចាំ៖ យ៉ូហានទី១ ៤៖៤** *"ពួកកូនតូចៗអើយអ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណ ទាំងនោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះ ដែលនៅក្នុង លោកីយ៍ ផង"។*

**ចំរៀង៖**

១. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

២. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

៣. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត



១.ឱ្យមនុស្សធំម្នាក់អង្គុយលើកៅអី ដោយដាក់ជើងបញ្ឈរឲ្យត្រង់ (ដូចរូប)

២. ហៅក្មេងតូចម្នាក់ឱ្យឈរនៅចំពោះមុខមនុស្សធំនោះ ហើយយកម្រាមដៃចង្អុលចុចចំកណ្តាលថ្ងាសរបស់មនុស្សធំនោះ។

៣.ប្រាប់មនុស្សធំនោះឱ្យព្យាយាមក្រោកឈរដោយមិនឲ្យប្រើដៃ ឬ មិនឲ្យឱនក្បាលទៅមុខ។ (ត្រូវអង្គុយ ឲ្យត្រង់ខ្លួន)។

៤.សួរកុមារផ្សេងទៀតតើពួកគេគិតថានរណានឹងឈ្នះក្មេងតូចឬ មនុស្សធំ?

៥.មើលទៅវាមិនទំនងទេថាមនុស្សធំម្នាក់នេះនឹងអាចក្រោកឈរបាន។ នេះជាហេតុផល៖ ដើម្បីក្រោកឈរឡើងមនុស្សធំម្នាក់នេះនឹងត្រូវប្តូរទម្ងន់របស់គាត់ទៅនៅនឹងជើង ដោយត្រូវឱនក្បាលគាត់ទៅមុខ នេះជាអ្វីដែលនឹងពិបាកព្រោះម្រាមដៃរបស់កុមារបានចុចថ្ងាស់របស់គាត់ជាប់ហើយ។ បើទោះជាមនុស្សធំម្នាក់នេះព្យាយាមក្រោកឈរបានក៏ដោយ ក៏គាត់ត្រូវការប្រឹងខ្លាំងណាស់ដែរ!

៦.បន្ទាប់ពីការប្រកួតចប់សូមរំលឹកកុមារថា មុនចាប់ផ្តើមប្រកួតពួកគេមិនបានគិតថាក្មេងតូចអាចនឹងឈ្នះទេ។ ប៉ុន្តែវាមានភាពងាយស្រួល នៅពេលកុមារធ្វើតាមការណែនាំរបស់គ្រូ។ ជាមួយព្រះក៏ដូចគ្នាដែរ ពេលខ្លះស្ថានភាពដែលមើលទៅហាក់ដូចជាមិនអាចទៅរួច តែវាមិនមែនមិនអាចទៅរួចទាំងអស់នោះទេ។ តែបើយើងធ្វើតាមការណែនាំរបស់ព្រះនោះយើងនឹងឈ្នះ។ ទ្រង់នឹងប្រទានអំណាចដល់យើងតាមរយៈព្រះយេស៊ូវ ។

### ៤. ការណែនាំមេរៀន

តើនរណាដែលប្រឆាំងជាមួយយើងនៅលើផែនដីនេះ? យើងប្រហែលជាគិតថា យើងត្រូវប្រឆាំងជាមួយនឹងមនុស្សដែលធ្វើឱ្យយើងឈឺចាប់។ ប៉ុន្តែសត្រូវពិតប្រាកដរបស់យើងមិនមែនជាមនុស្សទេ។ សត្រូវពិតប្រាកដរបស់យើងគឺជាអ្វី ដែលធ្វើឱ្យអ្នកដទៃឲ្យយើងមានភាពឈឺចាប់ដូចជា៖ កំហឹង ការច្រណែន

ប្រចណ្ឌ ភាពជូរចត់ និងការអន់ចិត្ត។ នៅពេលដែលមនុស្សម្នាក់មានអារម្មណ៍បែបនោះហើយ បើទោះជាវាមិនពាក់ពន្ធ័នឹងយើងក៏ដោយ ក៏គេអាចយកវាមកជះលើយើងបានដែរ។ ប្រហែលជាអ្នកបានស្រែកដាក់បងប្រុសឬបងស្រីរបស់អ្នក នៅពេលអ្នកខឹងខ្លាំងជាមួយនឹងឪពុកម្ដាយរបស់អ្នក។

ឬប្រហែលជាអ្នកធ្វើបាបមិត្តរបស់អ្នកនៅពេលអ្នកច្រណែនគាត់ខ្លាំង ដោយព្រោះតែមិត្តភក្តិរបស់អ្នកមានភាពរីករាយជាមួយមិត្តភក្តិផ្សេងទៀតជាងអ្នក។ ឬប្រហែល ជាអ្នកមិនគោរពឪពុកម្ដាយរបស់អ្នកនៅពេលអ្នក ភ័យខ្លាចថាពួកគេនឹងលែងលះគ្នា។ ប៉ុន្តែព្រះចង់ឱ្យ អ្នកដឹងថាទ្រង់ធំជាងអ្វីៗទាំងអស់ ដែលធ្វើឱ្យអ្នកឈឺចាប់។ ខគម្ពីរចងចាំថ្ងៃនេះប្រាប់យើងថា **១យ៉ូហាន ៤:៤** "ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះដែលនៅក្នុងលោកីយ៍ផង" ។ ព្រះធំ និងខ្លាំងជាងអារក្ស និងសត្រូវរបស់យើង ព្រះតែងតែឈ្នះលើពួកវា។ ថ្ងៃនេះយើងនឹងទៅស្ដាប់សាច់រឿងមួយពីរបៀប ដែលព្រះបានយកឈ្នះ ស្ថានភាពដែលមិនអាចទៅរួចក៏ដោយនោះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជនជាតិអ៊ីស្រាអែលបានត្រៀមខ្លួនរួចជាស្រេចដើម្បីចូលទៅទឹកដីសន្យា ប៉ុន្តែវាមិនមែនជារឿងងាយស្រួលទេ ពីព្រោះពួកគេត្រូវតែប្រយុទ្ធជាមួយនឹងសត្រូវខ្លាំងៗជាច្រើន។ ទីក្រុងដំបូងគេដែលព្រះបានប្រាប់យ៉ូស្វេឲ្យចាប់យកនោះគឺទីក្រុងយេរីខូរ។ នេះជាការងារដ៏លំបាកក្នុងការធ្វើ ពីព្រោះទីក្រុងយេរីខូរមានកំផែងពីរជាន់ដែលបានសាងសង់ជុំវិញទីក្រុង( សូមបោះពុម្ពរូបភាពហើយបង្ហាញក្រដាសរូបជញ្ជាំងទីក្រុងយេរីខូរឲ្យកុមារមើល )។ យ៉ូស្វេមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីអាចចូលទៅក្នុងទីក្រុងដែលមានជញ្ជាំងយ៉ាងរឹងមាំបែបនេះបាននោះទេ។ ប៉ុន្តែព្រះមានវិធីរបស់ទ្រង់ ព្រះអង្គបានប្រាប់ទៅយ៉ូស្វេឲ្យចាត់កងទ័ព របស់គាត់ដើរជុំវិញទីក្រុង ១ថ្ងៃម្ដងដងក្នុងរយៈពេល៦ថ្ងៃ។ ពួកគេបានផ្លុំត្រែនៅពេលដែលពួកគេដើរជុំវិញទីក្រុង។

នៅថ្ងៃទី៧ ព្រះបានប្រាប់យ៉ូស្វេឲ្យដើរជុំវិញទីក្រុងឲ្យបាន៧ដង។ មកដល់ជុំទី៧ ជនជាតិអ៊ីស្រាអែលបានផ្លុំត្រែឲ្យបានសំលេងវែងៗ ហើយលឺខ្លាំងៗ ហើយពួកគេបានបន្លឺសំឡេងស្រែកខ្លាំងៗ និងវែងៗ។ ទោះបីជាពួកគេមិនដឹងថា ហេតុអ្វីបានជាព្រះប្រាប់ពួកគេឲ្យដើរជុំវិញទីក្រុងក៏ដោយ ក៏ជនជាតិអ៊ីស្រាអែលស្ដាប់បង្គាប់តាមព្រះជាម្ចាស់ដែរ ហើយពួកគេបានឈ្នះការនេះ។ ជញ្ជាំងដ៏ក្រាស់បានដួលរលំ ជញ្ជាំងទីក្រុងបែរទៅជាដួលរាបស្មើ។

សូមចងចាំថា ការស្ដាប់បង្គាប់ព្រះគឺសំខាន់ណាស់។ ដូច្នេះយើងនឹងឈ្នះ ពីព្រោះព្រះនៃយើងតែងតែឈ្នះ។ ពេលដែលជីវិតរបស់យើងជួបនូវស្ថានភាពដ៏ធំមួយដែលវាហាក់ដូចជា ធំធេងពិបាកនឹងយកឈ្នះបាន យើងត្រូវការការជឿទុកចិត្តលើព្រះ ហើយយើងត្រូវដឹងថាព្រះតែងតែនៅខាងយើងជានិច្ច។

## ៦. សំនួរពិភាក្សា

១. តើទីក្រុងដែលជនជាតិអ៊ីស្រាអែលត្រូវដណ្ដើមយកនោះមានឈ្មោះអ្វី? ( *ទីក្រុងយេរីខូរ*)

២. តើហេតុអ្វីបានជាវាមានការពិបាកក្នុងការដណ្ដើមយកទីក្រុងនោះ?

( *ពួកគេមានជញ្ជាំងក្រាស់២ជាន់*)

៣. តើអ្វីដែលព្រះបានប្រាប់ឲ្យជនជាតិអ៊ីស្រាអែលធ្វើដើម្បីដណ្ដើមយកទីក្រុងនោះ? *( ពួកគេត្រូវដើរជុំវិញទីក្រុង១ថ្ងៃ១ដង និងផ្លុំត្រែ ឱ្យបាន៦ថ្ងៃ ហើយដល់ថ្ងៃទី៧ពួកគេត្រូវដើរជុំវិញទីក្រុងឱ្យបាន៧ដង ហើយមនុស្សគ្រប់គ្នាត្រូវស្រែកខ្លាំងទាំងអស់គ្នា)*

៤. តើមានអ្វីកើតឡើងនៅពេលដែលជនជាតិអ៊ីស្រាអែលស្តាប់បង្គាប់ព្រះក្នុងរយៈពេល៧ថ្ងៃនោះ ?
( *ជញ្ជាំងបានដួលរលំដោយខ្លួនឯង* )
៥. តើអ្នកអាចធ្វើអ្វីបានខ្លះនៅពេលដែលអ្នកមានបញ្ហានៅក្នុងជីវិត ? ( *អធិស្ឋាន ទុកចិត្ត និងស្តាប់បង្គាប់ព្រះ ពីព្រោះព្រះតែងតែឈ្នះ* )

**៧. ល្បែងកំសាន្ត** «ស្តាប់ឲ្យជាក់»




១.ចែកកុមារជា ពីរក្រុម ហើយជ្រើសរើសតំណាងក្រុមម្នាក់ពីក្រុមនីមួយៗ មកស្តាប់សារមួយប្រយោគពីគ្រូ ហើយពួកគាត់ត្រូវធ្វើជាអ្នកបញ្ជូនសារដល់ក្រុម ( ឧ.ជីងចក់ទំលើធាងចេកចាំចាប់ចំណី )
២. ឲ្យកុមារទាំង២ក្រុមឈរ បែរមុខផ្ទុយពីទិស ដែលមេក្រុមកំពុងស្តាប់ប្រយោគពីគ្រូ
៣.ហើយឲ្យមេក្រុមមកខ្សឹបដាក់ត្រចៀកកូនក្រុមម្នាក់ នូវប្រយោគដែលគ្រូបានប្រាប់ពួកគេ ( កុមារម្នាក់និយាយ ប្រយោគនោះបានតែម្តងប៉ុណ្ណោះ ) ។
៤.បន្ទាប់មកឲ្យកុមារខ្សឹបប្រយោគនោះតៗគ្នារហូតដល់អ្នកចុងក្រោយ ហើយកុមារចុងក្រោយនៅក្នុងក្រុមទាំង២ ត្រូវនិយាយ ប្រយោគនោះឡើងវិញឲ្យលឺៗ។
នៅពេលលេងល្បែងនេះចប់គ្រូត្រូវប្រាប់កុមារថា នៅពេលយើងស្តាប់បានល្អនោះ យើងនិងទទួលបានជ័យជម្នះ ដូចជាជនជាតិអ៊ីស្រាអែលដែរ។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន១ ៤៖៤** *“ពួកកូនតូចៗអើយ អ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណទាំង នោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកីយ៍ផង”*។

**៩. ហាត្ថកម្ម** « **ជញ្ជាំងអធិស្ឋាន**»

សម្ភារៈដែលត្រូវការ៖ ប៊ិក ស្កុតបិត និងដុំឥដ្ឋមួយចំនួន ( សូមបោះពុម្ពរូបដុំឥដ្ឋនៅទំព័រខាក្រោម )




១.សូមបោះពុម្ពក្រដាសនៅទំព័រខាងក្រោមហើយចែកឲ្យកុមារ។
២.សូមពន្យល់កុមារថាពួកគេអាចនឹងមានស្ថានភាព ដែលមើលទៅមិនអាចនឹងយកឈ្នះបាន។ ប្រហែលជាមាននរណា ម្នាក់ដែលពួកគេស្រលាញ់កំពុងតែឈឺ។ ប្រហែលជាពួកគេព្រួយបារម្ភពីសមាជិកគ្រួសារពួកគេដែលតែងតែឈ្លោះប្រកែកគ្នា។ ប្រហែលជាពួកគេដឹងថាមិត្តភក្តិរបស់ពួកគេមាន ទំលាប់មិនល្អ ប៉ុន្តែពួកគេមិនច្បាស់ថាពួកគេចង់ធ្វើអ្វីសំរាប់ការនេះ។ រឿងរ៉ាវទាំងនោះប្រៀបដូច ជាជញ្ជាំង ពីព្រោះវាជារឿងរ៉ាវធំ ដែលយើងត្រូវការព្រះមកជួយដោះស្រាយ។
៣.សូមឲ្យកុមារសរសេរ ឬគូររូបភាពពីការព្រួយបារម្ភនៅលើក្រដាសនោះ ( កុមារៗមិនចាំបាច់សរសេរឈ្មោះ បកស្រាយពីបញ្ហារបស់ពួកគេទេ )។
៤. កុមារអាចចេញមកបិទក្រដាសអធិស្ឋានរបស់ពួកគេនៅលើជញ្ជាំងម្តងម្នាក់ៗ។
៥.ពេលដែលគ្រប់គ្នាបានបិទក្រដាសរួចហើយ សូមឲ្យកុមារទាំងអស់ក្រោកឈរនៅខាងមុខជញ្ជាំងអធិស្ឋាននោះ ហើយស្រែកខ្លាំងៗឲ្យបាន៣ដងថា “ព្រះតែងតែឈ្នះ!” ។ ( គ្រូគួរតែអធិស្ឋានសំរាប់កុមារ )។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
សូមចំណាយពេល២ទៅ៣នាទី សរសេរពាក្យពីលក្ខណៈរបស់ព្រះឲ្យច្រើនតាមដែលអ្នកអាចធ្វើបាន ដើម្បីបង្ហាញៈ សូមលើកលក្ខណៈខ្លះៗរបស់ព្រះដូចជា ព្រះអង្គមានអំណាច ព្រះទ្រង់អត់ធ្មត់ ព្រះទ្រង់មានភាពថ្លៃប្រឌិត ហើយព្រះអង្គស្មោះត្រង់។ បន្ទាប់ពីបានបំពេញបញ្ជីហើយ សូមរក្សាវាទុកហើយប្រើវាសំរាប់ការថ្វាយបង្គំប្រចាំថ្ងៃ។ ជារៀងរាល់ថ្ងៃសូមសញ្ជឹងគិតអំពីលក្ខណៈមួយក្នុងចំណោមលក្ខណៈទាំងនេះ និងរបៀបដែលព្រះបាន បង្ហាញពីលក្ខណៈទាំងនោះនៅក្នុងជីវិតរបស់អ្នក។ សូមសរសើរ តម្កើងព្រះ ហើយទទួលស្គាល់កិច្ចការដ៏ អស្ចារ្យរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក។

# កំផែង២ជាន់នៃទីក្រុងយេរីខូរ



# ដុំឥដ្ឋនៃសេចក្ដីអធិស្ឋាន




